STATE OF WASHINGTON
DEPARTMENT OF SOCIAL AND HEALTH SERVICES
ECONOMIC SERVICES ADMINISTRATION (ESA)
DIVISION OF CHILD SUPPORT (DCS)

# លិខិតស្នើសុំពីអាសយដ្ឋាន

## Address Release Information Letter

(RCW 26.23.120 និង WAC 388-14A-2107)

ដល់ ៖ លេខសំណុំរឿង ៖

រដ្ឋបាលសេវាកម្មសេដ្ឋកិច្ច ផ្នែកជំនួយកុមារ អាចផ្តល់ឲ្យអ្នកនូវព័ត៌មានអាសយដ្ឋានភាគីផ្សេងទៀតដែលអនុវត្តដីកាជំនួយកុមាររបស់អ្នក ឬកូនពិត ឬចិញ្ចឹមរបស់អ្នក បើអ្នកបំពេញបានតាមតម្រូវការដូចតទៅនេះ ។

1. អ្នកត្រូវតែឲ្យ ESA / DCS នូវសេចក្តីថ្លែងការណ៍ជាលាយលក្ខអក្សរពីមូលហេតុដែលអ្នកចង់បានព័ត៌មានអាសយដ្ឋាន ។ ESA / DCS មានបែបបទដែលអ្នកអាចប្រើប្រាស់បាន ដែលហៅថា សំណើបង្ហាញអាសយដ្ឋាន ។
2. អ្នកត្រូវតែផ្តល់ឲ្យ ESA / DCS នូវសេចក្តីថ្លែងការណ៍ដែលតុលាការមិនបានផ្លាស់ប្តូរដីការបស់អ្នកទៅជាដាក់កំហិត បដិសេធ ឬផ្លាស់ប្តូរសិទ្ធិទៅសួរសុខទុក្ខរបស់អ្នក ឋានៈសិទ្ធិថែទាំកូនតាមច្បាប់ ឬសិទ្ធិចំណាយពេលនៅផ្ទះជាមួយកូន ។

ESA / DCS អាចបញ្ចេញព័ត៌មានអាសយដ្ឋានសម្រាប់តែមូលហេតុដូចតទៅនេះប៉ុណ្ណោះ ។

1. អ្នកអាចស្នើសុំពីអាសយដ្ឋានចុងក្រោយគេ ឬព័ត៌មានអាសយដ្ឋានរបស់និយោជកអំពីភាគីផ្សេងទៀតដែលអនុវត្តដីកាជំនួយកុមាររបស់អ្នក ។ អ្នកអាចប្រើប្រាស់ព័ត៌មាននេះសម្រាប់តែបង្កើត ជម្រុញ ឬកែប្រែដីកាជំនួយរបស់អ្នក ។
2. អ្នកអាចស្នើសុំពីអាសយដ្ឋានចុងក្រោយគេនៃកូនពិត ឬចិញ្ចឹមរបស់អ្នក ។ អ្នកត្រូវតែមានដីកាតុលាការដែលផ្តល់ឲ្យអ្នកនូវសិទ្ធិទៅសួរសុខទុក្ខជាមួយ សិទ្ធិថែទាំកូនតាមច្បាប់ ឬការចំណាយពេលនៅផ្ទះជាមួយកូន ។ អ្នកអាចប្រើប្រាស់ព័ត៌មាននេះសម្រាប់តែជម្រុញនៃសេចក្តីចែងក្នុងដីកាតុលាការរបស់អ្នក ។
3. អ្នកអាចស្នើសុំពីអាសយដ្ឋានចុងក្រោយគេនៃភាគីផ្សេងទៀតដែលអនុវត្តដីកាជំនួយរបស់អ្នក ។ អ្នកអាចប្រើប្រាស់ព័ត៌មាននេះសម្រាប់តែបង្កើតគម្រោងបែកគ្នារបស់ឪពុកម្តាយសម្រាប់កូនៗ ដែលបានដាក់ឈ្មោះក្នុងដីកាជំនួយ ។

អ្នក ឬមេធាវីរបស់អ្នកត្រូវតែបញ្ជូនត្រឡប់មកវិញនូវ*សំណើបង្ហាញអាសយដ្ឋាន*ដល់ DCS តាមអាសយដ្ឋានដែលមាននៅទំព័រទី 2 ។

1. អ្នកអាចបង្ហាញខ្លួននៅការិយាល័យ DCS ហើយបង្ហាញយើងពីអត្តសញ្ញាណសមរម្យ ។ បើមេធាវីរបស់អ្នកផ្ញើសំណើមកពួកយើងហើយ អ្នកមិនចាំបាច់បង្ហាញខ្លួនទេ ។
2. បើអ្នកបញ្ជូនសំណើតាមសំបុត្រ អ្នកត្រូវតែមានការបញ្ជាក់បែបបទ ។ បើមេធាវីរបស់អ្នកផ្ញើបែបបទមក DCS មេធាវីរបស់អ្នកមិនចាំបាច់បញ្ជាក់បែបបទទេ ។

សំណើសម្រាប់បញ្ចេញអាសយដ្ឋានរបស់ឪពុកឬម្តាយដែលទទួលសិទ្ធិចិញ្ចឹមកូន ឬអាសយដ្ឋានរបស់កូន ៖

មុននឹង ESA / DCS អាចផ្តល់ឲ្យឪពុកឬម្តាយដែលមិនបានទទួលសិទ្ធិចិញ្ចឹមកូននូវព័ត៌មានអាសយដ្ឋានរបស់ឪពុកឬម្តាយដែលទទួលសិទ្ធិចិញ្ចឹមកូន ឬរបស់កូន យើងត្រូវតែប្រាប់ឪពុកឬម្តាយដែលទទួលសិទ្ធិចិញ្ចឹមកូនពីសំណើនេះ ។ ឪពុកឬម្តាយដែលទទួលសិទ្ធិចិញ្ចឹមកូនមានពេល 30 ថ្ងៃដើម្បី ៖

1. ទទួលបានដីកាតុលាការដែលបញ្ឈប់ ESA / DCS បញ្ចេញអាសយដ្ឋាន ។
2. ផ្តល់ ឬទទួលបានដីកាតុលាការដែលដាក់កំហិតលើសិទ្ធិរបស់ឪពុកឬម្តាយដែលមិនបានទទួលសិទ្ធិចិញ្ចឹមកូនក្នុងការសួរសុខទុក្ខ ឬទាក់ទងឪពុកឬម្តាយដែលទទួលសិទ្ធិចិញ្ចឹមកូន ឬកូន ។
3. ទទួលបានដីកាតុលាការដែលបញ្ជាក់ពីសុខភាព សុវត្ថិភាព ឬសេរីភាពរបស់ឪពុកឬម្តាយដែលទទួលសិទ្ធិចិញ្ចឹមកូន ឬរបស់កូនដែលអាចមានហានិភ័យបើ ESA / DCS បញ្ចេញអាសយដ្ឋាន (WAC 388-14A-2114(1)(C)) ។
4. ស្នើសុំសវនាការដើម្បីប្រាប់ចៅក្រមច្បាប់រដ្ឋបាលមកពីការិយាល័យសវនាការរដ្ឋបាល (ទីភ្នាក់ងាររដ្ឋដាច់ដោយឡែក) ថា ESA / DCS មិនគួរបញ្ចេញអាសយដ្ឋានទេ ។

បើឪពុកឬម្តាយដែលទទួលសិទ្ធិចិញ្ចឹមកូនមិនបានស្នើសុំសវនាការទេ ESA / DCS នឹងឆ្លើយតបទៅនឹងសំណើរបស់អ្នកក្នុងរយៈពេល 45 ថ្ងៃ ។ DCS នឹងប្រាប់អ្នក
បើឪពុកឬម្តាយដែលទទួលសិទ្ធិចិញ្ចឹមកូន ស្នើសុំសវនាការ ។ អ្នកអាចចូលរួមក្នុងសវនាការ ។

បើ ESA / DCS មានហេតុផលជឿជាក់ថាការបញ្ចេញអាសយដ្ឋានអាចប៉ះពាល់ដល់ផ្លូវចិត្ត និងផ្លូវកាយរបស់ឪពុកឬម្តាយដែលទទួលសិទ្ធិចិញ្ចឹមកូន ឬរបស់កូន ESA / DCS នឹងមិនបញ្ចេញអាសយដ្ឋានទេ ។ ទោះបីជា ESA / DCS សម្រេចថាមិនបញ្ចេញអាសយដ្ឋាន ESA / DCS នឹងប្រាប់ឪពុកឬម្តាយដែលទទួលសិទ្ធិចិញ្ចឹមកូនអំពីសំណើ ។

សំណើសម្រាប់បញ្ចេញអាសយដ្ឋានរបស់ឪពុកឬម្តាយដែលមិនបានទទួលសិទ្ធិចិញ្ចឹមកូន ៖

ច្បាប់រដ្ឋវ៉ាស៊ីងតោនអនុញ្ញាតឲ្យ ESA / DCS បញ្ចេញអាសយដ្ឋានរបស់ឪពុកឬម្តាយដែលមិនបានទទួលសិទ្ធិចិញ្ចឹមកូនដល់ឪពុកឬម្តាយដែលទទួលសិទ្ធិចិញ្ចឹមកូនដោយគ្មានការជូនដំណឹងជាមុន លុះត្រាតែឪពុកឬម្តាយដែលមិនបានទទួលសិទ្ធិចិញ្ចឹមកូនបានស្នើសុំការជូនដំណឹងជាមុន ។ បើសិនជាឪពុកឬម្តាយដែលមិនបានទទួលសិទ្ធិចិញ្ចឹមកូនបានស្នើសុំការជូនដំណឹងជាមុន និតិវិធីបញ្ចេញដូចគ្នានឹងការបញ្ចេញអាសយដ្ឋានរបស់ឪពុកឬម្តាយដែលទទួលសិទ្ធិចិញ្ចឹមកូនដែរ ។ ទោះជាយ៉ាងណា បើ ESA / DCS មានហេតុផលជឿជាក់ថាការបញ្ចេញអាសយដ្ឋានរបស់ឪពុកឬម្តាយដែលមិនបានទទួលសិទ្ធិចិញ្ចឹមកូនអាចប៉ះពាល់ដល់ផ្លូវចិត្ត និងផ្លូវកាយរបស់ឪពុកឬម្តាយដែលមិនបានទទួលសិទ្ធិចិញ្ចឹមកូន ឬរបស់កូន ESA / DCS នឹងមិនបញ្ចេញអាសយដ្ឋានទេ ។

________________________
កាលបរិច្ឆេទ

______________________________________________
អ្នកតំណាងដែលបានផ្តល់សិទ្ធិឲ្យ
រដ្ឋបាលសេវាកម្មសេដ្ឋកិច្ច
អង្គភាពបញ្ចេញជាសាធារណៈ:

បើអ្នកមានសំណួរ សូមទាក់ទងមក ៖

DIVISION OF CHILD SUPPORT
PO BOX 11520
TACOMA WA 98411-5520

នៅក្នុងតំបន់ហៅទូរស័ព្ទ Olympia (360) 664-5000

នៅក្រៅតំបន់ហៅទូរស័ព្ទ Olympia (800) 457-6202

សេវាកម្ម TTY/TDD មានសម្រាប់អ្នកមានបញ្ហានិយាយ ឬស្តាប់ ។

សូមចូលទៅកាន់គេហទំព័ររបស់ពួកយើង ៖ www.dshs.wa.gov/esa/division-child-support

គ្មាននរណាម្នាក់ដោយសារតែជាតិសាសន៍ ពណ៌សម្បុរ សញ្ជាតិដើម ជំនឿ សាសនា ភេទ អាយុ ឬពិការភាព ត្រូវបានរើសអើងក្នុងការងារ សេវាកម្ម ឬផ្នែកទាំងឡាយនៃសកម្មភាពរបស់កម្មវិធី ។ បែបបទនេះមានក្នុងទំរង់ផ្សេងបើមានការស្នើសុំ ។